# ច្បាប់ស្រី
# ច្បាប់ប្រុស

មានជាវដុំនៅ

**បណ្ណាគារ**

**គិច ហុង**

តូបលេខ ១០ វិថីឧកញ៉ាផ្ទុង

ភ្នំពេញ

គ.ស.១៩៥៧

# ច្បាប់ស្រី និង ច្បាប់ប្រុស

(ចម្លងចេញពីសស្ត្រាស្លឹករឹត)

ការផ្សាយរបស់

**សម្រេកសិទ្ធ**

មានជាវដុំនៅ

**បណ្ណាគារ គិច ហុង**

តូបលេខ ១០ វិថីឧកញ៉ាផ្លុង

**ភ្នំពេញ**

គ.ស.១៩៥៧

# និវេទនកថា

អត្ថបទសៀវភៅ ច្បាប់ស្រី និង ច្បាប់ប្រុស ជាមត៌កស្នាដៃនិពន្ធដ៏ត្រចះត្រចង់ល្បីល្បាញលេចធ្លោបំផុតរបស់បណ្ឌិត ម៉ឹន មៃ (ឬកវី ម៉ឹន មៃ) គឺជាកម្រងច្បាប់ឱវាទរបស់ខ្មែរ ដើម្បីទូន្មានដល់ខ្មែរគ្រប់ប្រាណ បានបរិបូណ៌ដោយក្បួនអប់រំនូវសីលធម៌ គុណធម៌ សុជីវធម៌ និងចរិយាសាស្ត្រ សម្រាប់កុលបុត្រកុលធីតាខ្មែរ ព្រមទាំងមានវិសាលភាពនិងគុណតម្លៃដ៏មហិមា ហើយនៅតែមានឥទ្ធិពលយ៉ាងខ្លាំង ក្នុងសង្គមខ្មែររហូតមកដល់សព្វថ្ងៃ។

## ស្នាដៃសំខាន់ៗរបស់លោករួមមាន ៖

ច្បាប់ស្រី ៖ ជាកម្រងច្បាប់ទូន្មានដល់ស្ត្រីខ្មែរ ឆ្លុះបញ្ចាំងអំពីចរិយាមារយាទ សីលធម៌ អាកប្បកិរិយារម្យទម និងការរៀបចំខ្លួនប្រាណឱ្យបានសមរម្យ មានលក្ខណៈសមសួនល្អប្រពៃក្នុងគ្រួសារ និងភាពថ្លៃថ្នូរនៅក្នុងសង្គម។

ច្បាប់ប្រុស ៖ ជាក្បួនអប់រំសម្រាប់បុរសខ្មែរ ផ្ដោតលើគុណធម៌ ចរិយាធម៌ និងសុជីវធម៌ ដើម្បីឱ្យមានបែបបទសណ្ដាប់ធ្នាប់ក្នុងការរស់នៅ។

ស្នាដៃទាំងនេះត្រូវបានគេចាត់ទុកថាជាទស្សនវិជ្ជាខ្មែរ និងជាមូលដ្ឋានគ្រឹះនៃការអប់រំតាមបែបបុរាណ។ លោកបានបួសរៀនចំណេះដឹងជ្រៅជ្រះផ្នែកខាងភាសាបាលី និងអក្សរសាស្ត្រជាតិ មុននឹងចាកសិក្ខាបទមកបម្រើរាជការ ហើយបានបន្សល់ទុកនូវស្នាដៃជាអមតៈដល់សង្គមខ្មែរ។

ច្បាប់ស្រី គឺជាក្រមសីលធម៌ សម្រាប់ស្ត្រីខ្មែរ។ និពន្ធតាមទម្រង់កំណាព្យ គឺជាខ្សែចងទៅកាន់ច្បាប់ប្រុស ដែលអនុវត្តចំពោះបុរស។ ច្បាប់ស្រីរៀបរាប់លម្អិតពីដំបូន្មានរបស់ម្ដាយចំពោះកូនស្រី ដែលទើបរៀបការ។ ម្ដាយជាអ្នកនិទានរឿងណែនាំកូនស្រីឱ្យរក្សាសន្តិភាពក្នុងផ្ទះ ដើរហើរនិងនិយាយស្ដីទន់ភ្លន់ ស្ដាប់បង្គាប់និងគោរពប្ដី។ ហើយបានក្លាយជាចំណុចកណ្ដាលនៃការជជែកដេញដោល និងភាពចម្រូងចម្រាសក្នុងប៉ុន្មានឆ្នាំថ្មីៗនេះក្នុងប្រទេសកម្ពុជាផងដែរ។

ប្រវត្តិសាស្ត្រនៃប្រភពដើម ទស្សនៈដូនតារបស់ស្ត្រី ច្បាប់ស្រី គឺជាកំណាព្យមួយដែលត្រូវបាននិយាយដោយផ្ទាល់មាត់តាំងពីសតវត្សទី១៤ ដល់ទី១៩ មុនពេលអត្ថបទនេះត្រូវបានសរសេរជាលាយលក្ខណ៍អក្សរ។

មកដល់ពេលនេះ យើងខ្ញុំមានការសោកស្ដាយយ៉ាងក្រៃលែងចំពោះលោកបណ្ឌិត ម៉ឺន មៃ ដែលជាកវីនិពន្ធដ៏ឆ្នើមមួយរូប ពុំបានបន្សល់ទុកនូវជីវប្រវត្តិរបស់លោកឡើយ ដោយយើងអាចស្គាល់ពីរូបលោកបាន តាមរយៈនាមបញ្ញត្តិរបស់លោកតែប៉ុណ្ណោះ។ លោកកវីមានទេពកោសលសម្បយុត្តដោយវីរិយភាពបានតាក់តែងនូវកម្រងពាក្យកាព្យ ដែលជាស្នាដៃនិពន្ធដ៏សំខាន់ចំនួន ២ ក្រោមចំណងជើងថា"ច្បាប់ស្រី" និង"ច្បាប់ប្រុស"។

ជាអវសាននៃនិវេទនកថានេះ សូមឱ្យវិញ្ញាណក្ខន្ធបណ្ឌិត ម៉ឺន មៃ បានទៅសោយសុខក្នុងសុគតិសួគ៌ទេវលោក និងសម្បត្តិព្រះនិព្វានកុំបីឃ្លៀងឃ្លាតឡើយ។

- អត្ថបទកំណាព្យ ច្បាប់ស្រី និង ច្បាប់ប្រុស របស់បណ្ឌិត ម៉ឺន មៃ
- បានចម្លងសាជាថ្មីឡើងវិញ នៅថ្ងៃចន្ទ ទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦

# មាតិកា

**ឈ្មោះអត្ថបទ ........................................... ទំព័រ**

និវេទនកថា ........................................................................ក

មាតិកា ............................................................................គ

**ច្បាប់ស្រី** ................................................................១

ពន្យល់ពាក្យ ......................................................................១៦

លេខយោងក្នុងវង់ក្រចក .....................................................១៧

**ច្បាប់ប្រុស** ..............................................................១៩

ពន្យល់ពាក្យ.......................................................................៣១

# ច្បាប់ស្រី

## និពន្ធដោយបណ្ឌិត ម៉ឺន មៃ

## បទកុជង្គលីលា

នេះបទកំណាត់ចង់ជា កុជង្គលីលា ចង់ជាច្បាប់ស្រី។
កាលនាងឥន្ទវតី ចរចាកតាមប្ដី គឺបុណ្ណកយក្ស[១] ។
នាងវិមលាជាព្រះមាតា បើកបន្ទូលថា ហៃកូនពិសី។
នាងនឹងត្រាច់ត្រង់តាមប្ដី ចេញចាកអំពី ពិភពនាគនេះ។
ទៅស្ថានមនុស្សលោកនាយអេះ ចូរនាងចាំចេះ បម្រើស្វាមី។
ធ្វើវត្តប្រតិបត្តិប្រក្រតី កុំឱ្យស្វាមី អាក់អន់ចិន្ដា។
នាងអើយគម្លែង[២]ក្រឡា ជាម្ចាស់សិរសា កូនកុំមាក់ងាយ។
ហៃកូនស្រីស្ងួនមាសម្ដាយ ក្រណាស់នាងអើយ តាមដោយច្បាប់ស្រី។
ក្រមួយមិនបានសម្ដី ពាក្យទន់តិចនៃ ឱ្យញាតិចូលចិត្ត។
ក្រមួយមិនចេះរិះគិត ឃើញញាតិឆ្ងាយជិត ហៅឡើងធីស្វា។

ទោះមានមិនមានក្តីណា ពាក្យផ្អែមចរចា ទើបគេស្រឡាញ់។
កុំជួចិត្តស្ទូរកំណាញ់ មិនមានអស់អញ នឹងញាតិសន្តាន។
កើតយសរបស់ផងបាន កើតសុខក្សេមក្សាន្ត ពីព្រោះកូនស្រី។
ទោះនឹងនិយាយស្រដី ការកេរ្តិ៍ជាស្រី កុំស្តីឡេះឡោះ។
ថាលេងដូចក្មេងញ៉េះញ៉ោះ ឃើញប្រុសកំលោះ សសៀរចូលជិត។
សើចព្រៀងកញ្ឆៀងមិនគិត ប្រុសព្រើលបានចិត្ត ទាហានដោយសារ។
ហៅស្រីអប្រីយ៍ឥតការ ឥតមានឥរិយា មារយាទក្នុងខ្លួន។
សើរើពុំធ្វើនឹងនួន ស្រដីមិនមួន មិនមានអៀនអន់។
ឃើញគេបៀងបែរគយគន់ សើចសួរចំអន់ ចំអកឱ្យប្រុស។
ហៅស្រីអប្រីយ៍ទុយ៌ស មិនខ្លាចខ្លួនខុស មារយាទគ្រឹត្យក្រម។
ធ្វើការអង្គុយច្រឡំ នឹងសមពុំសម ផ្សាឯងជាស្រី។
មិនកោតមិនខ្លាចចិត្តប្តី ឱ្យប្រុសដទៃ មាក់ងាយប្តីណា។
ហៅស្រីឥតលក្ខណា ឥតមានឥរិយា មារយាទពុំសម។
ធ្វើការផងណាប្រើខំ ទោះត្បាញចាក់ដំ នាងខំឱ្យហើយ។
កុំទុកទៅមុខទៀតឡើយ ថាចាំបង្អើយ កម្រណាស់ណា។
ទោះធ្វើហូលគោមគាត[៣]ផ្កា ដាក់ត្បាញហើយណា បានស្រេចសឹមធ្វើ។

ធ្វើឱ្យកើតកេរ្តិ៍ប្រសើរ ហើយកុំឱ្យដើរ លេងផ្ទះគេណា។
ឱ!ស្ងួនខ្ញីមខ្លួនរក្សា នាងខំធ្វើការ ទាន់ខ្លួនក្រមុំ។
មានប្ដីបានអ្វីជាខំ រវល់កូនឃុំ កម្រចេះធ្មៀត។
ព្រួយចិត្តគំនិតចង្អៀត មួយហើយមួយទៀត យំទារតែស៊ី។
រីងព្រួយទាំងមួយទាំងពីរ រកបានឱ្យស៊ី ទើបបានបាត់មាត់។
ទោះកាន់ការធ្វើឱ្យស្អាត់ ហូលគោមគាតកាត់ អន្ទងត្បាញទៅ។
កុំទុកក្នុងស្នុគស្នូញនៅ ក្រែងដល់យូរទៅ ខាតខូចអសារ។
ហៃកូនស្រីស្ងួនមាតា ចូរចាំរក្សា កុំភ្លេចស្មារតី។
ចូររករៀនយកច្បាប់ស្រី ឱ្យកោតខ្លាចប្ដី គម្លែងក្រឡា។
ធ្វើវត្តប្រតិបត្តិសោតណា ឱ្យនាងរក្សា ភ្នក់ភ្លើងទាំងបី។
ឱ្យកាត់ឱ្យគង់ប្រក្រតី សព្វថ្ងៃកុំបី ភ្លេចផ្ដុំឱ្យឆេះ។
ក្រែងវាលដួចដាលព្រាយប្រេះ កើតក្ដៅរលេះ រលោកអស់អង្គ។
ភ្លើងក្រៅកុំនាំទៅក្នុង ឱ្យឆេះបំផ្លុង រីងផ្ដុំបង្កាត់។
ភ្លើងក្នុងមិនប្រុងប្រយ័ត្ន នាំមកបង្កាត់ ឱ្យឆេះឯក្រៅ។
អុជអាលបណ្ដាលឱ្យក្ដៅ ដាលដល់កូនចៅ អសោចអប្រីយ៍។
ឱ្យនាងខំប្រុងស្មារតី មើលភ្លើងទាំងបី រក្សាឱ្យគង់។

ភ្លើងនោះឱ្យគុណពុំលង់ នឹងបានឧត្តុង ឧត្តមកន្ទង់ ។
កើតយសរបស់ទ្រព្យផង បរិបូណ៌ឥតហ្មង ប្រសើរក្តាត់ណា ។
ភ្លើងមួយនោះឱ្យរក្សា គឺគុណមាតា បិតាស្ងួនគ្រង់ ។
ឱ្យនាងធ្វើដោយគន្ធង់ ប្រណិប័តន៍កុំឆ្គង់ នឹងម្ដាយឪពុក ។
ឱ្យខំថែទាំញ៉ុកញ៉ុក ចំណីចំណុក ចំណង់អាត្មា ។
កុំឃ្លានទុកស៊ីឡើយណា ឆ្ងាញ់ឈ្ងុយពិសា ជូនជាប្រក្រតី ។
ពាក្យពេចន៍ការកិច្ចអ្វីៗ អត់ឱនកុំបី ឱ្យអាក់ចិន្តា ។
ភ្លើងមួយគម្តែងក្រឡា គឺប្តីអាត្មា បិតថេររួមរ័ក្ស ។
ឱ្យនាងប្រណិប័តន៍ជៀងជាក់ កុំធ្វើឱ្យអាក់ ឱ្យអន់ចិត្តប្តី ។
អន់ឱនខ្វាចខ្លួនជាស្រី កុំឱ្យស្រដី ទុកគេជាស្មើ ។
ទោះកើតហេតុភេទសារពើ ពាក្យពុំប្រសើរ ជញ្ជឹងចាំស្តាប់ ។
ទោះប្តីស្រដីពុំគាប់ ពុំគួរឱ្យប្រាប់ បានដឹងដល់ម្តាយ ។
កើតខឹងវែងវីងខ្វរខ្វាយ ឮពាក្យពីម្តាយ ខ្សឹបខ្សៀវប្រាប់ប្តី ។
មិនក្សាន្តបែកបានពីរបី កើតជាសម្តី សួរចុះសួរឡើង ។
ពុំស្ងាត់ស្ងៀមមាត់ចចើង ជជែកនាំឡើង ចចើងមិនបាត់ ។
តតាំងពាក្យខ្លាំងមិនស្ងាត់ មិនស្ងៀមឱ្យបាត់ ឱ្យបានទីសុខ ។

ជជែកស្មើរបែកទាំងស្រុក មិនមានហៅសុខ យូរលង់ឡើយនៃ ។
នេះហៅក្អក់ភ្លើងទាំងបី ម្ដាយផ្ដាំកូនស្រី ឱ្យខំរក្សា ។
នាងអើយគម្ដែងក្រឡា ខុសត្គងម្ដេចម្ដា ម្ដាយផ្ដាំកូនស្រី ។
ឱ្យអត់សង្កត់ហឫទ័យ កូនកុំស្រដី ដើមប្ដីកំបាំង ។
កុំជេរកុំចេញជាខ្លាំង ខ្សត់ខ្សោយខ្មៅខ្វាំង នាងកុំមើលងាយ ។
លួងខ្សោយប្រើឱ្យនិយាយ ណែនាំលេងលាយ ឱ្យស្រួលវាចា ។
ទោះប្ដីស្រដីម្ដេចម្ដា ខេងខឹងជេរថា បោះពាក្យទម្ងន់ ។
ក្រោធក្រេវធុលឆេវមិនអន់ មិនអាក់ស្រាកស្រន់ ដោយចិត្តគ្នាន់ក្នាញ់ ។
រទូរទាំទន្ទេញ ជេរថាជន្ទេញ ដ្បិតទាស់នឹងចិត្ត ។
ឱ្យកូនស្រីស្ងួនខំអត់ ឱ្យបានរលត់ រលាយកំហឹង ។
កុំឱ្យកាន់ខ្លួនប្រែប្រឹង តតបទៅនឹង អ្នកជាស្វាមី ។
ខេងខឹងក្រញឹង[២]សម្ដី មិនគិតខ្លួនស្រី ស្រដីទ្រគោះ ។
ប្រកែកស្ដីពាក្យគំរោះ គំរាមបញ្ឆោះ បញ្ឆោរឱ្យខឹង ។
រឹងរូសមើលមុខសម្ងឹង សម្ងក់ទៅរឹង ចចើងនាំឈ្លោះ ។
រឹងឆ្ងងឆ្លើយពាក្យបញ្ឆោះ បំបែកជាឈ្លោះ បំបែរមិនទៀង ។
ជេរថាត្មែធ្មាបំព្រៀង ដៀលត្មះបញ្ឆៀង បញ្ឈឺចិត្តប្ដី ។

*បោកបោះទ្រគោះអ្វីៗ ចាប់បោលទៅដី បែកបាក់ពុំគិត។*
*មិនស្រួលទទួលបាត់មាត់ មួះម្នេញក្នុងចិត្ត ឱ្យបានប្ដីចាញ់។*
*ទើបបានសុខចិត្តជាវិញ ហៅស្រីមួះម្នេញ អាប់កេរ្ដិ៍យសឆ្ងាយ។*
*ហៃកូនស្រីស្ងួនមាសម្ដាយ ខុសណាស់នាងអាយ កុំធ្វើដូចគេ។*
*ទោះបីបើប្ដីនាងជេរ នាងចូលទៅឯ ដំណេកគិតសិន។*
*ចេញមកនាងយកពាក្យទន់ ស្រដីឱ្យអន់ ស្រាយទោសនោះទៅ។*
*ទោះបីបើប្ដីប្រដៅ ចូរនាងចាំនៅ ទុកក្នុងអាត្មា។*
*ពាក្យពេចន៍ពុំភ្លេចឡើយណា ក្រែងឆ្គងម្ដេចម្ដា ដ្បិតបានផ្ដាំស្រាប់។*
*ព្រោះឯងមិនក្រែងមិនស្ដាប់ ពាក្យគេបង្គាប់ បង្អើតតែឈ្មោះ។*
*ឥតសុខអាក្រក់តែឈ្មោះ ឮតែប្រឈ្មោះ មិនចេះហៅល្ហែ។*
*នេះពុំរាប់ជាស្រ្តីទេ ជាអ្នកប៉ោឡែ ចិត្តចោរដកទង។*
*ឱ្យមាត់បង្រ្គបប្ដីផង ឱ្យគេស្ដាប់ហោង ថាឯងគ្រាន់បើ។*
*គឺមោះនាងនោះមិនប្រើ មិនបើកឱ្យដើរ បញ្ជើឱ្យទេ។*
*ទោះបីប្ដីប្រើមាសមេ កុំកួនដំអែ(៧) ដំអក់មិនទៅ។*
*ឆ្ងាយជិតកុំនិត្យរង់នៅ ក្រោកក្រេសដើរទៅ កុំឱ្យប្ដីជេរ។*
*កុំទៅយូរនៅផ្ទះគេ រវល់ទំនេរ វៀសមកណា។*

ឱ!កូនខ្ញុំមខ្លួនមាតា ជាស្រីនេះណា កម្រណាស់នាង។
មិនថាផ្សិតល្អរូបរាង មិនរើសផ្សិតជាង បេះការទាំងគ្រប់។
មិនបានស្គាល់ទីគោរព ស្គាល់តែឧបទ្រព ទាំងដប់ប្រការ។
ហៅតែនឹងល្អរូបា តិចហើយបេះការ គួរកោតដោយយ៉ាង។
មួយល្អរូបសសន្ទាង(៦) ឥតគេផ្ទឹមខាង ច្បាប់ផងមិនបេះ។
ល្អពិតគំនិតមិនផេះ ទោះខ្មៅក្រផេះ ការសោតសមគួរ។
គឺមោះនាងនោះមិនជួ បេះដឹងសមគួរ ស្គាល់អស់ឥរិយា។
នេះឯងពីព្រេងលោកថា ហៅល្អរូបា កបកល្យាណី។
ហៃកូនស្រីស្ងួនពិសី ម្ដាយប្រាប់អំពី ឧបទ្រពចង្រៃ។
កាន់ក្បាលប្ដីហើយរកថៃ មិនបានលើកដៃ ពិតទូលសំពះ។
លោកទុកស្មើកុកទំផ្ទះ រង្គុំរង្គុះ នឹងបង់អស់ទ្រព្យ។
កន្ទង់ដើងប្ដីពុំគាប់ ព្រោះចិត្តចង់ឆាប់ រំលងដើងប្ដី។
ស្មើសត្វលលកខ្មោចខ្មី ហើរប្រាសអប្រីយ៍ កើតព្យាធិរោគា។
ចង្រៃមួយនៃរាល់គ្នា ចេញចូលមាត់ទ្វារ ពុំបានបិទបាំង។
ផ្ទេសប្រាណខុសខានមិនរាំង មិនរុញបំបាំង មើលយល់សាយសុស។
ទុកស្មើគេអុជចន្ទុះ ឱ្យចោរចូលចុះ យកទ្រព្យទាំងឡាយ។

ស្រីមួយសើចលេងក្អាកក្អាយ ឮលេចចម្ងាយ រំលងផ្ទះបី ។
ស្មើសត្វចចាត[៧]បក្សី ចូលភូមិផងក្តី ចង្រៃក្តាត់ណា ។
ស្រីមួយដេកដាក់កាយា ប្រះប្រែអាត្មា ឱ្យខ្ពង់ទៅប្តី ។
ទុកស្មើពស់ក្រាយ[៨]អប្រិយ៍ ឡើងផ្ទះឥតបី ឥតបើគណនា ។
ចង្រៃកាចក្រៃពុំជា រីងព្រាត់ប្រាសគ្នា ពុំបានវែងឆ្ងាយ ។
ស្រីមួយសក់វែងអន្ទាយ រំសុសរំសាយ សក់សោតរេរា ។
នៅមាត់អណ្តូងមាត់ទ្វារ បីដូចមដ្ឋរា ឆ្មាលាក់ក្រចក ។
ចង្រៃឥតបីបើរក រេរាសំកក មិនចុកសក់ង៉ាយ ។
ស្រីមួយដើរទៅទាត់ជាយ ឮលាន់ស្មើរផ្ងាយ ប្រឹថពីសន្ទឹក ។
សំពត់ដាច់ដាចមិនគិត ដើរឮគគឹក ស្មើសូររន្ទះ ។
ញុាំញុើដំណើររលះ ដាក់ជើងលើផ្ទះ គគ្រាំគគ្រេង ។
កក្រើកទាំងផ្ទះបីល្វែង ដូចកលគេសែង របស់ចេញទៅ ។
ស្រីមួយឃើញទ្រព្យនៅផ្លូវ កន្ទងហួសទៅ មិនចាប់ចេញទុក ។
ពុំថេរចំណេរទៅមុខ ពុំចេះដាក់ទុក រាយរាល់តែល្វែង ។
ទ្រព្យនោះរលស់ចេញឯង ចង្រៃទាស់ទែង ធ្វើឱ្យអន្តរាយ ។
ទោះធីចំណីនូវបាយ លបលួចកកាយ ពម[៩]ពុំសណ្តាប់ ។

កូនអើយនេះហើយចូរស្ដាប់  ហៅក្ដីឧបទ្រព  ទាំងដប់ប្រការ ។
ឱ្យជៀសអស់ទាំងនេះណា  ឱ្យរៀនលក្ខណា  ទាំងប្រាំពីរផង ។
គឺព្រះមានបុណ្យកន្ទង់  ទេសនាចែងចង់  ជាបទគាថា ។
មួយមាតុមួយមិត្តភរិយា  ភាតុភរិយាជា  ទាសភរិយាផង ។
ទាំងបួនប្រសើរឥតហ្មង  គួរឱ្យចាំចង  ទុកក្នុងអង្គា ។
រីឯហៅមាតុភរិយា  ប្រពន្ធនោះជា  លោកទុកស្មើម្ដាយ ។
ចរិតបីប្រការក្នុងកាយ  មួយចង់ខ្វល់ខ្វាយ  ប្រយោជន៍ឱ្យប្ដី ។
បានថ្កើងរុងរឿងឮល្បី  មិនឱ្យអាប់ប្ដី  ចាស់ស្លៀកខ្លួនឯង ។
ចេះរៀបរណ្ដាប់តាក់តែង  ចំណីផងស្ងែង  រកមកឱ្យប្ដី ។
មួយបើប្ដីឈឺថ្កាត់អ្វី  ព្រួយប្រឹងមើលប្ដី  រកថ្នាំសង្កូវ ។
រកពេទ្យមេមត់នូវគ្រូ  គ្រោះយាមគន់គូរ  មើលប្ដីឱ្យជា ។
រីឯហៅភាតុភរិយា  ប្រសើរសោភា  ប្រពន្ធស្មើបង ។
នោះមានចរិតពីរហោង  ដូចប្អូននិងបង  ចិត្តមូលមួយប្រាណ ។
មួយធ្វើឱ្យប្ដីក្សេមក្សាន្ត  របស់ប្ដីបាន  ចេះទុករក្សា ។
មួយទោះឮពាក្យអ្នកណា  គេតិះដៀលថា  ស្រដីពីប្ដី ។
ពុំត្រូវអាស្រូវអប្រីយ៍  ចេះការកេរ្ដិ៍ប្ដី  បែរបានជាសុខ ។

ទោះបីបើប្តីមានទុក្ខ គិតឱ្យបានសុខ យកខ្លួនជានា ។
មួយសោតឯមិត្តភរិយា មានចរិតជា បីប្រការមិញ ។
បីដូចកលមិត្តសម្លាញ់ មានចិត្តអស់អញ មិនឱ្យមានហ្មង ។
បីដូចកលប្អូននិងបង ប្រាសយូរលង់ហោង ទើបមកជួបគ្នា ។
មានចិត្តប្រតិព័ទ្ធមហិមា ដ្បិតបានជួបគ្នា មិនឱ្យមានហ្មង ។
មួយមានមារយាទកន្ទង ទោះឃើញប្រុសផង មិនល្មៀងចិត្តទៅ។
រីទាសភរិយានោះក្លូវ ក្នុងមាត្រាត្រូវ ប្រពន្ធខ្ញុំប្តី ។
ចរិតប្រាំបីប្រការខ្មី មួយចិត្តខ្លាចប្តី ក្រែងប្តីវាយដេរ ។
ប្រុងចិត្តការគិតខ្មាសគេ មិនឱ្យប្តីដេរ បន្ទោសខ្លួនបាន ។
ទោះខឹងប្តីក្រៃប៉ុន្មាន មិនចេះហៅហ៊ាន ឆ្លើយឈ្មោះតមាត់ ។
មួយទោះប្តីនោះកាចក្តាត់ ខឹងដល់វាយវាត់ ដេរចោរដកទង ។
មិនហ៊ានឆ្លើយឈ្មោះរំលង តតបទៅផង ក្រែងព្មកេរ្តិ៍ឆ្ងាយ ។
មួយចេះប្រដាប់រៀបបាយ ប្តីដើរជិតឆ្ងាយ មិនហ៊ានបរិភោគ ។
អត់ទ្រាំទម្រាំប្តីមក ជួបជុំទើបយក បរិភោគផងគ្នា ។
នេះឯងហៅទាសភរិយា សម្តេចភគវា ទេសនាប្រោសប្រាប់ ។
បើអស់ស្រីណាបានស្តាប់ យកទុកជាច្បាប់ ក្នុងប្រាណសព្វថ្ងៃ ។

លុះអស់អាយុក្សិណក្ស័យ បានទៅកើតឰ តុសិតសួគ៌នាយ។
នឹងបានក្សេមក្សាន្តពណ្ណរាយ សេពសុខសប្បាយ និរទុក្ខភយា។
រីឯប្រពន្ធពុំជា ពេជ្ឈឃាតករិយា ចរិតមានបួន។
កុំឱ្យយកទុកក្នុងខ្លួន ឱ្យជៀសចេញជួន កើតកម្មវេរា។
មួយចិត្តគំនិតចង់ជា ឆ្ងាសធ្វើយបំពារ បំពានឱ្យប្ដី។
ប្រទូស្តរឹងរូសខ្វះខ្វី មិនចេះចាញ់ប្ដី ថាឯងគ្រាន់បើ។
ធ្វើយធ្ងង់សួរសង់បណ្ដើរ ចង់ឈ្មោះឱ្យស្មើ ឱ្យលើសប្ដីវិញ។
មួយមិនចង់ធ្វើបំពេញ បង្គាប់ប្ដីវិញ ឱ្យថ្កើងខ្លួនឯង។
អាងចេះជៀលតិះពុំក្រែង ឱ្យប្ដីស្ដាប់ឯង ដោយចិត្តអន្ធពាល។
មួយមានចិត្តនោះស្រើបស្រាល ចង់ត្រេកត្រអាល ចោរចេញក្បត់ប្ដី។
មួយចិត្តទ្រើសទ្រុស្តអប្រិយ៍ ចង់សម្លាប់ប្ដី ស្រឡាញ់ប្រុសទៀត។
គិតកាប់សម្លាប់បង្បៀត នឹងយកប្រុសទៀត ធ្វើប្ដីមរណា។
រីឯសត្រូវករិយា ចរិតពុំជា ប្រាំពីរប្រការ។
មួយមិនខ្លាចប្ដីអាត្មា បង្គាប់ត្រង់ណា ពុំធ្វើតាមចិត្ត។
មួយទ្រឹងទ្រមឹងស្ងៀមស្ងាត់ ប្ដីសួរបីម៉ាត់ ពុំស្រដីផង។
មួយប្ដីស្រដីគន្ធង ប្រដៅច្បាប់ផង ពុំចូលចិត្តស្ដាប់។

មួយមិនចង់ឱ្យប្ដីគាប់ មិនចង់ប្រដាប់ ឱ្យប្ដីថ្កុំថ្កើង ។
មួយទោះនឹងស្រដីឡើង ពាក្យធំចចើង ចចេសនឹងប្ដី ។
មួយទោះប្ដីលោះខ្ញុំស្រី វាបម្រើប្ដី មិនឱ្យអាក់អន់ ។
ឃើញគាប់រឹងស្អប់ក្នាញ់ក្នាន់ ក្នុងចិត្តប្រច័ណ្ឌ ជេរថានាយអាយ ។
មួយផ្សិតប្ដីមានសហាយ ហួរហែកសុសសាយ ឱ្យប្ដីអាស្រូវ ។
រីចោរភរិយានោះកូវ ចរិតពុំត្រូវ មានបីប្រការ ។
មួយចង់ចាយទ្រព្យប្ដីណា ឱ្យខូចអសារ មិនគង់ជាល្អ ។
មួយប្ដីឃ្មាតខ្មីខំរក របស់បានមក មិនថែទាំទុក ។
លួចឱ្យទៅម្ដាយឪពុក ប្ដីសួររកមុខ មិនប្រាប់ឡើយណា ។
មួយខ្ជិលមិនចង់ធ្វើការ កុហកមុសា ថាឯងរវល់ ។
ដេកលេងចំខែងអស់កល លុះប្ដីគេយល់ ពុតធ្វើជាឈឺ ។
ទទូរដេកថ្ងូរហ៊ឺៗ ប្ដីហៅមិនឮ ពុតចង់តែស្លាប់ ។
នេះហៅប្រពន្ធពុំគាប់ ស្រីណាកាន់ខ្ជាប់ ពុំដែលរសាយ ។
លុះអស់អាយុក្ស័យក្ស័យ ធ្លាក់ទៅអបាយ ទាំងប្អូនជំពូក ។
តែងនឹងរងទុក្ខរងសោក រំដោះរួចមក កើតជាមនុស្សខ្វើយ ។
ហេតុអកុសលនេះហើយ ផ្សិតខ្លួនឥតត្រើយ ធ្វើខុសគន្លង ។

ខុសវត្តប្រតិបត្តិផ្តាំផ្តង មិនរៀនមិនរង ខុសនឹងច្បាប់ស្រី។
មាក់ងាយនោះមានប្រាំបី មានក្នុងបាលី ព្រះធម៌លោកថា។
មាក់ងាយមួយនោះឯងណា ដ្បិតប្តីពិការ មិនបានមួនមាំ។
ខឹងស្អប់ធុញថប់មិនទ្រាំ មិនមានរកថ្នាំ ត្រូវគ្រោះមេមត់។
មើលប្តីឱ្យជាធាប់ធុត ខឹងវិញមិនអត់ បន់ប្តីឱ្យស្លាប់។
មាក់ងាយមួយប្តីខ្សត់ទ្រព្យ គ្មានកេរកោះគាប់ ស្មើនឹងអាត្មា។
ដៀលត្មះថាប្រាសដោយសារ ព្រោះខ្ជិលធ្វើការ ទើបគ្មានរបស់។
មាក់ងាយដ្បិតប្តីអប្បយស ឯងត្រកូលខ្ពស់ ពូជពង្សពុំស្មើ។
ធ្មើងខ្លួនឱ្យប្តីបម្រើ ឈ្មោះឡើងហើយដើរ ដៀលត្មះពូជពង្ស។
មាក់ងាយមួយដ្បិតប្តីល្ងង់ ខ្លៅខ្លួនទ្រមង់ ទ្រមក់យឺតយូរ។
ដៀលត្មះពុំចេះអាសូរ សម្តីខ្មោះខ្មួរ មិនក្រែងប៉ុនសក់។
មាក់ងាយមួយប្តីអាក្រក់ សាច់ខ្មៅប៉ប៉ក់ មុខអុតស៊ីសុស។
កន្ទ្រលរោងរលក្រឱះ សក់ស្កាញស្កូវសុស ពោះធំប៉ុនពាង។
ខ្លួនឯងចិញ្ចែងរូបរាង ខ្លួនសល្អជាង ថាប្តីមិនសម។
មាក់ងាយមួយប្តីមិនខំ ធ្វើការលោលាំ ឡេវឡាវដើរលេង។
ធ្មៀតធ្មើយបោះពាក្យគគ្រេង ឈ្មោះដេរមិនឈ្វេង គិតខុសមាត្រា។

| | | |
|---|---|---|
| មាក់ង៉ាយមួយប្ដីផឹកស្រា | ស្រវឹងចោលការ | ដើរលេងតែលតោល ។ |
| ពាក្យក្មេងរាំច្រៀងឡោៗ | ឱ្យក្ដៅព្រុសតោ | ផ្ដើលក្ញាក់កូនចៅ។ |
| ព្ធមាត់ប្ដីហើយខឹងក្ដៅ | ប្រទេចដេរទៅ | តាមដោយចិត្តក្នាញ់ ។ |
| មាក់ង៉ាយមួយទៀតនោះមិញ | ដ្បិតប្ដីស្រឡាញ់ | លលូកប្រឡែង ។ |
| មួលក្អិចចាក់ចុចជាល្បែង | មិនមានកោតក្រែង | បានចិត្តដេរវិញ ។ |
| ដ្បិតតែយល់គេស្រឡាញ់ | សម្ដីផងមិញ | គំរោះគំរើយ ។ |
| ធ្វើក្នាញ់បែរចេញព្រងើយ | ខេខឹងកន្ដើយ | ក្អិចក្អក់ចរិយា ។ |
| ពុំបានក្បេមក្សាន្តនឹងគ្នា | មាក់ង៉ាយនេះជា | គម្រប់ប្រាំពីរ ។ |
| កូនអើយនេះហើយច្បាប់ស្រី | ឱ្យកូនពិសី | រករៀនរក្សា ។ |
| យកទុកក្នុងអង្គអាត្មា | ប្រសើរក្ដាត់ណា | កើតសុខសួស្ដី ។ |
| ប្រសើរទាំងនាលោកីយ៍ | ទោះបរលោកក្ដី | សឹងលុះប្រាថ្នា ។ |
| ទោះចិត្តគន់គិតសច្ចា | ជាពុទ្ធមាតា | សឹងបានបរិបូណ៌ ។ |
| ដូចចិត្តធុតធាប់ពុំយូរ | កបកើតសម្បូណ៌ | សម្បត្តិទ្រព្យផង ។ |
| កើតយសខ្ពង់ខ្ពស់កន្ទង់ | យឺនយូរឥតហ្មង់ | ដូចក្ដីប្រាថ្នា ។ |
| ច្បាប់នេះឧត្តមថ្លៃថ្លា | ទោះស្រីឯណា | ព្ធហើយមានភ័ព្វ ។ |
| ជាល្អកម្របានស្ដាប់ | ស្ដាប់ចូរចិត្តចាប់ | ចូរចាំគ្រប់គ្នា ។ |

*បានដល់មគ្គផលសួគ៌ា ប្រសើរសោភា ចូរចាំកុំភ្លេច ។*

*ចរចាអស់អាថ៌ពាក្យពេចន៍ ពាក្យឥតកាព្យកិច្ច បរិបូណ៌ប្រពៃ ។*

*ប្រាជ្ញប្រែវឹងនាមនៃ ខ្ញុំឈ្មោះម៉ឺន ម៉ែ មែនមានសទ្ធា ។*

*មានចិត្តក្លួចគិតកាព្យា កបកើតជ្រះថ្លា ត្រេកត្រង់កុសល ។*

*សច្ចាប្រាថ្នាមគ្គផល ផុលផុសយោបល់ លេចលើកទុកនៅ ។*

*ទោះបីសេចក្តីខុសត្រូវ សូមទានតម្រូវ ទុកតសាសនា ។*

*សម្រាប់ជាច្បាប់មាត្រា សូរេចប្រការ បរិបូណ៌ថែងចប់ ៕*

**=ចប់=**

# ពន្យល់ពាក្យ

| | |
|---|---|
| *កុជង្គលីលា* | = *នាគដើរ* |
| *គម្លែងក្រឡា* | = *ជាធំលើផែនដី* |
| *អស់អញ* | = *អើពើ, រាប់រក, រវល់* |
| *ការកេរ្តិ៍* | = *រក្សាកេរ្តិ៍, ការពារកេរ្តិ៍* |
| *ទុយ៌ស* | = *ថោកទាប, អាក្រក់* |
| *អសារ* | = *គ្មានប្រយោជន៍, អាក្រក់* |
| *អសោចិអប្រិយ៍* | = *ស្អុយអាក្រក់* |
| *ពុំលង៍* | = *ពុំឃ្លរ* |
| *ជន្ទេញ* | = *លួកល, ជន្ល* |
| *បំព្រៀង* | = *ថោកទាប* |
| *ប៉ោទ្បែ* | = *ឥតទៀងទាត់កន្លែង* |
| *ដកទង៍* | = *ពាក្យជេរទៅលើមនុស្សស្រី* |
| *ផ្ទឹមខាង* | = *ផ្ទឹមក្បែរ, ផ្ទឹមជាមួយ* |

| | |
|---|---|
| **កល្យាណី** | = ស្រីជាមិត្តគួរស្រឡាញ់ |
| **ពិតទូល** | = លើកដៃសំពះឡើងលើ (បន្ទូល) |
| **បទគាថា** | = សេចក្ដីជាវគ្គឃ្លា |
| **តុសិត** | = ឈ្មោះស្ថានសួគ៌ជាន់ទី ៤ |
| **ពណ្ណរាយ** | = ធ្វើឱ្យមានពណ៌ព្រោងព្រាយ |
| **និរទុក្ខភយា** | = ឆ្ងាយពីទុក្ខភ័យ |
| **អន្ធពាល** | = កាចកំឡៅ, ឆឹងឆឹតឆ្ងុល |
| **អបាយ** | = ស្ថាននរក |

# លេខយោងក្នុងវង់ក្រចក

(១)- តាមទម្លាប់ គេអានថា **ប៉ុន-ណាក់-យក្សា** ។

(២)- **គម្ដែង** គំម្ដែង ដើង ដ ឬ គំ-ម៉ៈ ដែង (ន.) (ក្លាយឃ្លាតមកពីពាក្យខ្មែរ ក្នុងសម័យបុរាណព្រេងនាយថា ក្រម្រតាង> ក្រម្រតេង> ក្រម្រតែង) មានន័យថា ព្រះតេជព្រះគុណ; លោកជាម្ចាស់ ។ លុះចំណេរកាលតៗមក ខ្មែរយើងប្រើពាក្យនេះ សំដៅសេចក្ដីថា លោកអ្នកមានបុណ្យច្រើនគួរជាទីគោរព គួរធ្វើសក្ការបូជា; លោកអ្នកមានស័ក្តិយសខ្ពង់ខ្ពស់ ។ គម្ដែងក្រឡា ស្វាមី, ប្ដី ។ គម្ដែងផ្ទៃក្រោមព្រះរាជា,

ក្សត្រិយ៍ទ្រង់រាជ្យ (មើលក្នុងពាក្យ ផ្ដៃ ទៀតផង) ។ គម្ដែងសង្ឃ ព្រះភិក្ខុសង្ឃជាទីគោរព : បពិត្រព្រះគម្ដែងសង្ឃ.... ។

**(៣)- គាត** (សំ.) ន. សូត្រដែលចងរុំជាក្បាច់ ដើម្បីនឹងធ្វើសំពត់ហូល : ចងគាត, ជ្រលក់គាត ។ (គួរប្រើ **គាធ** មានន័យជាក់ច្បាស់ជាង **គាត**) ។

**(៤)- ក្រញឹង** (កិ. វិ.) ពាក្យសម្រាប់ចម្រើនពាក្យខឹងឱ្យឃើញប្លែកឡើង: ខឹងក្រញឹង។

**(៥)- ចំអែ** (កិ.) បំពើងទ្រូងទៅមុខ : អង្គុយចំអែ, ឈរចំអែ ។ ចំអៀកចំអែ ចំអែ ដោយចំអៀក ។

**(៦)- សន្លាង** សន់-ល៉ាង (គុ.) សជ្រះស្អាត: សសន្លាង។ ថ្មីទែង, ថ្មីស្អាត : ថ្មីសន្លាង។ ដែលល្អសមរម្យមិនគ្គង: ល្អសន្លាង, រូបល្អសន្លាង ។

**(៧)- ចចាត** (ន.) សត្វបក្សីមួយប្រភេទ សម្បុរខៀវខាងខ្នង ខាងក្បាល ឯខាងពោះក្រហម ក្បាលធំចំពុះក្រហម បរិភោគត្រីជាអាហារ ជាសត្វដេញផ្កាក់ : ចចាតផ្កាក់, ទាក់ចចាត, ហ្មចចាត ។

**(៨)- ក្រាយ** (ន.) ឈ្មោះពស់មួយប្រភេទមានពិសខ្លាំង មានធ្មេញទ្រនុងខ្នង ជាអាវុធ អាចប្រាសឱ្យមុតបាន : ពស់ក្រាយ ។

**(៩)- ពម** (កិ.) ចាប់អាហារដោយដៃ ដាក់ក្នុងមាត់ខ្លួនឯង ពមបាយ ។ ពមញាត់ៗ (ពមញាត់-ពមញាត់) ពមដោយចាប់ញាត់ៗ ប្រញាប់ប្រញាល់ ឱ្យបានឆាប់ឆ្អែត : ស៊ី ឆាប់ឡើងពមញាត់ៗទៅ! (ព. សា., ព. ស្ន.) ។

# ច្បាប់ប្រុស

## និពន្ធដោយបណ្ឌិត មុឺន ម៉ៃ

## បទព្រហ្មគីតិ

| | |
|---|---|
| នេះបទព្រហ្មគីតិ | ពីព្រេងព្រឹទ្ធទុកទូន្មាន |
| ថែងចងជានិទាន | ទុកគ្រាន់មើលជាច្បាប់ថ្មី។ |
| ឱ្យអស់កូនចៅក្រោយ | ស្តាប់កុំឱ្យភ្លេចស្មារតី |
| ប្រដៅទាំងប្រុសស្រី | យកទុកខ្លួនគ្រប់អាត្មា។ |
| ជម្មតាកើតជាមនុស្ស | ទោះស្រីប្រុសក្រណាស់ណា |
| ត្រូវគិតក្នុងចិន្តា | ឱ្យបានដឹងសមនិងគួរ។ |
| នឹងអស់ញាតិសន្តាន | សោះគេមានពាក្យថាជួ |
| កុំឆ្មើងកុំតែងតួ | ធ្វើកំប៉ោងកុំពាក្យធំ។ |
| នឹងដើរដូចកុជង្គ | ឱ្យឱនអង្គអាចបារម្ភ |
| ឱ្យត្រូវនឹងច្បាប់ក្រម | គួរប្រតិបត្តិកុំឱ្យឆ្គង។ |
| រៀនបទរៀនបាទចាស់ | កុំប្រឡាសលើរៀមច្បង |

ស្រដីនឹងអ្នកផង ពាក្យឱ្យគួរកុំឯងរ៉ឺ។
អឺអើអញដាច់សាច់ ឆ្គងពាក្យពេចន៍គេស្រដី
ដើមដៀលឱ្យអប្រិយ ស្រដីថាកូនអត់ពូជ។
ចាស់ទុំមិនប្រដៅ ជេរកូនចៅទើបវាខូច
គេថាកូនឥតពូជ មិនដឹងច្បាប់នឹងចាស់ទុំ។
គេដៀលដល់ម៉ែឪ គេរឹ្កអាស្រូវស្អុយរហ៊ុំ
គេស្តីដើមជៀវជុំ ដំនៀលនោះមកដល់ចាស់។
កុំកាចកុំស្លូតពេក កុំចំអៀកវៀនរហ័ស
កុំខ្វាចកុំហ៊ានណាស់ ឱ្យរំពឹងរំពៃគ្រប់។
ទោះដេកឱ្យរហ័ស ភ្ញាក់មុនចាស់ដោះឡើងលុប
មុខមាត់មើលឱ្យគ្រប់ ទ្រព្យរបស់សឹមដេកវិញ។
ស្លាម្លូស៊ីឱ្យច្រៀក កុំបីបៀកទាំងមូលមិញ
តូចធំឱ្យច្រៀកចេញ តាមពាក្យចាស់ថាអភ័ព្វ។
ដេកយប់កុំដេកយូរ ហើយទទូរដូចគេងាប់
សំពត់ស្បៀកឱ្យខ្ជាប់ កុំឱ្យអាក្រាតក្រៅខ្លួន។
នឹងដេកកុំទ្រមក់ ឱ្យលង់លក់ក្រៅពីក្បួន
បើភ្ញាក់ឱ្យដឹងខ្លួន ឡើងអង្គុយកុំមាត់ខ្វាំង។

ប្រែប្រាណប្រុងវិញ្ញាណ
ខ្លាចក្រែងមានចោរចិត្តខ្លាំង
ប្រួញប្រាណប្រុងជញ្ជាំង
ជញ្ជូនទ្រព្យលួចយកចេញ។
បើឥតមោះមន្ទិល
កុំឱ្យខ្ជិលដេកទៅវិញ
ភ្ញាក់ហើយឱ្យក្រោកចេញ
រកជក់ថ្នាំស៊ីម្លូស្លា។
ទោះពេលពន់ព្រលប់
គន់ឱ្យគ្រប់ទ្រព្យនានា
កាំបិតខាងអាត្មា
ឱ្យសិតទឹកដាក់ចុងជើង។
ប្រអប់ដាក់ទឹមស្នា
ថ្វាយទេព្តារក្សាយើង
ហើយឱ្យបំពក់ភ្លើង
នៅក្រានក្រៅកុំឱ្យដាច់។
កុំឱ្យអស់រលីង
រលត់ធេងហើយថាភ្លេច
សព្វថ្ងៃមើលកុំដាច់
កុំដើរយកពីផ្ទះគេ។
ថៃទាំមើលជើងក្រាន
ឱ្យឧសមានកុំទំនេរ
បង្កាត់បង្កើតកេរ្តិ៍
កុំប្រហែសឱ្យស្វូន្យសុង។
ប្រយ័ត្នក្រែងក្រងាយ
ពុំសប្បាយឈឺពោះពុង
បង្កាត់កម្តៅអង្គ
អុជបំភ្លឺមើលនេះនោះ។
មានកាលយប់ងងឹត
ភ្លេចមិនគិតជួនកូនជុះ
គ្មានភ្លើងអុជចន្លុះ
ក្រានរលុះរលត់ធេង។
រត់រកភ្លើងសស្រោក់
ព្រួយលំបាកតែខ្លួនឯង

*ហេតុខ្ជិលពុំគិតក្រែង ក្រយប់ថ្ងៃព្រួយដើរឆ្ងាយ។*
*ហើយឱ្យថៃទាំទឹក ទោះយប់ព្រឹកកុំគិតឆ្ងាយ*
*ដងដាក់ក្អមរាត់រាយ សព្វពួចពាងអាងអុងធំ។*
*កុំឱ្យស្ងួតក្អមជេង អស់រលីងពាងធំៗ*
*គ្មានសោះនោះមិនសម ជួនក្រែងក្រឆ្ងាយយប់ថ្ងៃ។*
*ទោះដើរទៅឆ្ងាយជិត កាន់កាំបិតកំដរដៃ*
*ក្រែងមានមែកឈើព្រៃ កាប់កាន់មកទុកជាឧស។*
*ជួនកាលក្រែងបន្ទា មុតអាត្មាគ្រាន់ចាក់ជួស*
*ជាគ្រឿងគ្រប់មិនខុស ការសត្រូវទោះឆ្មាំក្ដៃ។*
*ដើរព្រៃឱ្យមើលលើ ឃើញស្លឹកឈើជាបន្ទៃ*
*កាប់កាន់កុំដៃទេ អង្គុយគន់មើលឆ្វេងស្ដាំ។*
*ក្រែងមានឈើព្រៃផ្សាប់ គួរកាច់កាប់យកជាថ្នាំ*
*ផ្សើក្រានគ្រាន់ដណ្ដាំ បាយបានឆ្អិនឆាប់ដូចចិត្ត។*
*សោះស្រីស្រដីបាន បើឧសមានមិនព្រួយចិត្ត*
*សព្វថ្ងៃប្រុងគំនិត ថៃទាំទើបគង់របស់។*
*មាសប្រាក់ស្រូវអង្ករ ទុកឱ្យល្អកុំសប្បុរស*
*សំចៃកុំឱ្យអស់ មើលថៃជួនខ្លួនឯងណា។*

*សូវស្លួចកុំឱ្យដាច់ បើវាតិចឱ្យឧស្សាហ៍*
*រិះរកផ្សំទៀតណា ឱ្យបានច្រើនក្រវើនទុក។*
*នឹងចាយឱ្យគិតក្រោយ ទោះនឹងឱ្យៗ មើលមុខ*
*កុំឱ្យស៊ុកគ្រលុក ទោះនឹងទុកឱ្យចំណាំ។*
*រដូវធ្វើចម្ការ ឱ្យឧស្សាហ៍គ្រឿងគ្រាប់ដាំ*
*ស្វឹកគ្រៃខ្ចីត្រប់ត្រុំ ត្រាវត្រសក់សព្វបន្លែ ។*
*កុំខ្ជិលកុំប្រអូស ទៅផ្ងសរត់សុំគេ*
*គេមិនឱ្យឯងទេ តែគឺមោះព្រោះខ្ជិលដាំ។*
*ទោះធ្វើស្រែចម្ការ ឱ្យឧស្សាហ៍មើលថែទាំ*
*កុំខ្ជិលកុំប្រចាំ ចបចូកជីកស្មៅល្អិតផង។*
*កុំឱ្យខាតកម្លាំង ទោះខែប្រាំងប្រើឱ្យដង*
*ទឹកទៅស្រោចស្រប់ផង ឱ្យលូតលាស់មានផ្កាផ្លែ ។*
*ធ្វើការកុំគិតព្រួយ ខ្លួនឯងមួយកុំត្អូញត្អែរ*
*ខ្ជាំងខ្សោយកុំឱ្យល្ហែ ខ្ជាចតែនឿយហើយមិនធ្វើ។*
*ជាងយប់បិតឬស្សី ត្បាញជាល្អីតោកញើ*
*កុំឱ្យស្រីស្ដីលើ ឥតអំពើធ្វើលេងទៅ។*
*កុំទុកដៃទទេ ជាងទំនេរបោចស្មៅព្រៅ*

*ខាងផ្ទះខាងលំនៅ ឱ្យវាលកាលកើតសុខា។*

*ឱ្យមានក្ដីបារម្ភ ធ្វើស្រែកុំចោលចម្ការ*

*ដឹងដែកកាំបិតព្រា ទុកឱ្យជាកុំឱ្យបាត់។*

*ដេកយប់ឱ្យរាំងទ្វារ ទ្រព្យជាៗប្រុងប្រយ័ត្ន*

*ត្រចៀកចាំកុំភ្ញាត់ កុំភ្លេចចោលមិនដឹងខ្លួន។*

*ប្រយ័ត្នប្រយោជន៍យូរ ទោះលក់ដូរមើលថែថួន*

*ទោះទ្រព្យរបស់ខ្លួន ឱ្យសួរកូនសួរប្រពន្ធ។*

*កុំអាងឯងជាប្រុស ចាយរបស់មិនគិតគន់*

*មិនដឹងដល់ប្រពន្ធ ព្រមព្រៀងគ្នាឥតបើថា។*

*ទោះបីបើបងប្អូន ពឹងរកខ្លួនទៅណាៗ*

*ទោះទៅលេងឥតការ ឥតគេរកដើរឆ្ងាយជិត។*

*ឱ្យប្រាប់អ្នកនៅផ្ទះ កុំរលះឥតគំនិត*

*គេភ័យព្រួយចិត្តគិត ព្រោះមិនដឹងជាទៅណា។*

*បើទៅជាមានភ័ព្វ ប្រសើរគាប់នោះឥតថា*

*ប្រសិនពានពស់ខ្លា ខ្យល់ចាប់ចុកឥតគេសម។*

*ទោះដើរមានដំណឹង ឱ្យរំពឹងគិតបារម្ភ*

*នឹងដើរៗ ឱ្យសម យប់ព្រលប់ឱ្យមាត់ក។*

កុំស្មៀមកុំស្ងាត់ពួន លបលាក់ខ្លួនខ្លាចមិនល្អ
ឱ្យមើលឱ្យមាត់ក ដើរឱ្យស្មោះសោះគេថា។
ទោះខ្លួនជាប៉ុន្មាន ពាក្យសន្តានវៃឆ្មុសា
គេម៉ែមកអាត្មា តាមដំណឹងដំណើរខុស។
កូនអើយបាកុំភ្លោយ កុំផ្ទាប់ឱ្យអាប់កេរ្តិ៍យស
ធម្មតាកើតជាប្រុស ឱ្យរករៀនច្បាប់មាត្រា។
លោកថាហៅឆ្លួតបី មួយឆ្លួតស្រីមួយឆ្លួតស្រា
មួយឆ្លួតល្បែងពាលា លេងបៀប៉ោជួកំតាត់។
ទាក់មាន់ទាក់ទទា ជល់ភ្នាល់គ្នាបរបាញ់សត្វ
អន្ទាក់ដាក់បង្កាត់ ល្បែងអស់នោះមិនកំណើត។
ធម្មតាប៉ោនិងបៀ មិនដែលខ្មែរណានឹងកើត
មិនឮមានកំណើត មានតែលិចលង់ខ្លួនទេ។
ជួនកាលគេចាញ់ឯង រៀងរាល់ល្បែងតែនឹងវេ
មានកាលឯងចាញ់គេ កុំទុកចិត្តថាឯងប៉ិន។
ពីព្រឹកស្មៀកហូលជរ ល្ងាចស្មៀកសខ្វះចង់ក្បិន
ពីព្រឹកត្បូកក្បាលចិន ល្ងាចមិនទាន់ចិនដាក់ខ្នោះ។
ជួនកាលវាចងជើង ព្យួរខ្ពស់ឡើងក្បាលដាំចុះ

*ក្អែកស្ទឹងតឹងក្រញុំ*
*វាទារប្រាក់ឱ្យបានឆាប់។*
*មើលមុខល្អតិចអី*
*មិនខ្មាសស្រីផ្សារឈរស្តាប់*
*មុខមិញដូចគេស្លាប់*
*មាត់ស្ទេញស្ទាញពេបដូចក្មេង។*
*ស្រែកថ្ងូរអេះអូយអឺយ*
*អាចិកអើយអាណិតលែង*
*អញរកប្រាក់ឱ្យឯង*
*ឱ្យអាចិកស្អែកនេះបាន។*
*ចិនឮព្រមស្រាយមក*
*បណ្តើររកប្រាក់សន្តាន*
*តឹងទារទាល់តែបាន*
*ទ្រព្យឱ្យទៅទើបវាលែង។*
*អ្នកអាយអ្នកអើយកុំ*
*គួរបារម្ភពាល់តែល្បែង*
*កុំលកុំលូកលេង*
*គួរឱ្យវាងឱ្យវៀរសោះ។*
*កុំឈរកុំឈប់ជិត*
*ក្រែងមិនអត់បង់កេរ្តិ៍កោះ*
*កុំល្បងល្បែងនោះសោះ*
*គួរឱ្យដោះឱ្យដើរចេញ។*
*ច្បាប់នេះជាប់ពាល់ខ្លួន*
*ទោះបងប្អូនមិត្តសម្លាញ់*
*ពឹងខ្លួនឯងឱ្យចេញ*
*ជានាទ្រព្យគ្នាយកទៅ។*
*ឯទ្រព្យបានទៅវា*
*ឯងជានាស្រាប់តែនៅ*
*វាបានទ្រព្យយកទៅ*
*ខ្លួនឯងនៅជានាស្រាប់។*
*ដល់គេមកតឹងទារ*
*អ្នកជានាឱ្យបានឆាប់*
*មិនបានគេប្រចាប់*
*ទៅជាខ្ញុំព្រោះជានា។*

*ទោះបងប្អូនធុរៈ ក្រជំពាក់គេតឹងទារ*
*បើមានទ្រព្យជួយជា កុំជានាំណាអ្នកអាយ។*
*កូនអើយចូរបាចាំ ឪពុកផ្ដាំកុំបីណាយ*
*ប្រយ័ត្នរាល់រូបកាយ កុំឱ្យក្មេចពាក្យនេះណា។*
*មួយទៀតហៅធ្ងូតស្រី គួរកុំបីសេពកាមា*
*វាតែងទាញអាត្មា នាំវង្វេងក្មេចបាបបុណ្យ។*
*ក្មេចទានសីលសូន្យសោះ ក្មេចឃ្នាងខ្នោះដល់ជីពជន្ម*
*ក្មេចទោសក្មេចទាំងគុណ ក្មេចទាំងការកាន់រសាយ។*
*បង្កើតតែទុក្ខទោស បើបានសុខសឹងប្រែក្លាយ*
*បង្កើតក្ដៅក្រហាយ ឱ្យទាស់ទែងខឹងនឹងគ្នា។*
*ចងទោសគុំគង្គួន មិនគិតខ្លួនខ្លាចមរណា*
*មានកាលក្នុយនិងមា គុំធ្វើគ្នាឱ្យសោះសូន្យ។*
*បង្កើតតែចិត្តជំ ចៅគំនុំនឹងជីដូន*
*ឯបងខឹងនឹងប្អូន ម្ដាយនិងកូនគុំធ្វើគ្នា។*
*រីខ្ញុំគុំកាប់ម្ចាស់ ឱ្យក្ដៅណាស់ក្នុងអង្គា*
*កើតទោសខឹងនឹងគ្នា ជាគំនុំពុំត្រាស្បើយ។*
*មានកាលគេដាក់ឃ្នាង វាមិនរាងចាលចិត្តឡើយ*

*លក់ព្ន័យខ្ញុំគេហើយ មិនខ្លាចស្លាប់ដល់អាត្មា។*
*គេកាប់ដោតទាំងក្បាល មិនចេះចាលចិត្តឡើយណា*
*ក្មេចខ្លួនសូន្យសោះសា នឹកតែត្រង់សេពសប្បាយ។*
*រីឯកាមកិលេស កុំប្រហែសគួរឱ្យណាយ*
*ស្អិតណាស់ណាអ្នកអាយ អ្នកអើយកុំគិតសង្ស័យ។*
*នេះឯងហៅធ្លួតស្រី គួរកុំបីឱ្យអាល័យ*
*ចូរចងចាំសព្វថ្ងៃ ទុកទូន្មានអង្គអាត្មា។*
*អ្នកប្រាជ្ញលោកនិទាន ទុកទូន្មានពល់រូបា*
*មួយហៅធ្លួតសុរា នោះកុំផឹកវាស្រវឹង។*
*វានាំក្មេចវិញ្ញាណ ក្មេចសីលទានសោះសូន្យឈឹង*
*ផឹកហើយមិនដែលនឹង នាំចិត្តនោះឱ្យធំក្រៃ។*
*ឯខ្លួនឯងតូចទេ មើលទៅគេប៉ុនមេដៃ*
*កម្លាំងឯងស្មើថៃ មិនកោតគេតិចឡើយណា។*
*ក្អេងក្អាងពាក្យកក្អែ អ្នួតពូកែបទបានស្រា*
*មិនមានខ្លាចនរណា ស្រដីកោងរកកលឈ្លោះ។*
*បញ្ចោរបញ្ចៀសផ្តាស ជេរវាងវាសមិនចំឈ្មោះ*
*នាំហេតុតែខាងឈ្លោះ ផ្ញើយធ្ងងពាក្យឱ្យបានទាក់។*

*ប្រពន្ធឃើញឃាត់ទៅ ប្ដីមិនត្រូវថាកុំអ្នក*
*ឯងខឹងលោវាយជាក់ ដោយចិត្តធំបទបានស្រា។*
*មានកាលជួនស្រវឹង ពុំមានដឹងខ្លួនឡើយណា*
*ដើរដួលដេកផ្កាប់ផ្ងារ ស្រាតសំពត់អស់ពុំដឹង។*
*គេឃើញអស់ខ្មាសក្មុំ ក្មេងមកជុំសើចទ្រហឹង*
*ដេកដូចគេស្លាប់ឈឹង ក្អែកក្អួតពាសពេញទាំងខ្លួន។*
*កំណើតអ្នកផឹកស្រា កុំអួតថាឯងនឹងនួន*
*ផឹកហើយស្រវឹងមួន ខ្លួនខ្សត់ទេអួតថាមាន។*
*អ្នកស្លូតទៅជាកាច ឯអ្នកខ្លាចទៅជាហ៊ាន*
*ខុសត្រូវទៅបំពាន បំពុលខ្លួនឱ្យបានបាប។*
*នេះឯងហៅធ្លួតស្រា ក្នុងធម៌ថាពៀរដរាប*
*អ្នកណាផឹកហើយបាប បង់កិត្តិយសពុំសួស្តី។*
*គួរកុំសេពសុរា នាំអាត្មាឱ្យអប្រិយ*
*នឹងធ្លាក់ទៅអវិចី នរករងទុក្ខវេទនា។*
*ហៃអស់ជនទាំងឡាយ កុំវាយមាយក្នុងអង្គា*
*ចូរស្ដាប់ច្បាប់នេះណា ទុកទូន្មានខ្លួនសព្វថ្ងៃ។*
*នេះឯងហៅធ្លួតបី លោកស្រដីក្នុងធម៌ថ្លៃ*

បើអ្នកណាមួយនៃ
នឹកប្រាថ្នាដោយចំណង់។
លោកចង់ជាឧបមា
ឱ្យអ្នកណាមួយផ្ចិតផ្ចង់
យកដែកដុលបោះបង់
ក្នុងភ្លើងក្រានឆេះប្រាលឆ្អៅ។
បើកាន់ដែកដែលដុត
នោះមិនមុតមានតែក្តៅ
កាន់បាននោះទើបហៅ
ចិត្តមុតមែនមិនគិតប្រាណ។
នោះទើបលោកឱ្យធ្វើ
នូវអំពើទាំងបីបាន
ដោយធម៌ពីបុរាណ
លោកឧបមាដូច្នេះណា។
ចាត់ចែងតែងជាបទ
ព្រហ្មប្រាកដកាលបិតា
ប្រដៅខ្ញុំនេះណា
សព្វសេចក្តីដូច្នេះនៃ។
កិច្ចកាព្យពាយរៀបរស
ខ្ញុំនាមឈ្មោះបណ្ឌិត មៃ
គិតចង់ជាសេចក្តី
ប្រដៅជនចប់ម៉្ងៃះហោង ៕

= ចប់ =

# ពន្យល់ពាក្យ

| | |
|---|---|
| *វៀមច្បង* | = បង់បង្អស់ |
| *អាង៍អុង៍* | = ពាង៍ធំៗ |
| *វាលកាល* | = វាលស្រឡះ |
| *វែង៍មុសា* | = វមែង៍ពោលប្រកាន់ |
| *ព្ន័យ, ពិន័យ* | = ផាក, ប្រាប់ផាក |
| *កាមកិលេស* | = សេចក្តីប្រាថ្នាជាចំណង៍ |
| *បទបានស្រា* | = ព្រោះបានស្រា |
| *ស្រវឹង៍មួន* | = ស្រវឹង៍ខ្លាំង៍ |
| *សេពសុរា* | = ប្រព្រឹត្តស្រា |
| *អវិចី* | = ស្ថាននរកយ៉ាង៍ជ្រៅ |

មានជាវជុំនៅ

## បណ្ណាគារ

## គិច ហុង

តូបលេខ ១០ វិថីឧកញ៉ាផុង

# ភ្នំពេញ

គ.ស.១៩៥៧